ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

លេខ: ៩៩៤ ឧរថ ឧរសម-ប្រក

# ប្រកាស
## ស្តីពី
## ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សេចក្តីជូនដំណឹងលេខ ១៣២៤ ឧរថ.ម.ម.ជ.សជណ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការអនុវត្តន៍ច្បាប់មាត្រាសាស្ត្រកម្ពុជា
- យោងតម្រូវការការងារចាំបាច់ផ្នែកមាត្រាសាស្ត្រ ។

## សម្រេច

**ប្រការ១:** បង្កើតពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា សម្រាប់បញ្ជាក់ពីភាពត្រឹមត្រូវក្នុងការប្រើប្រាស់ និងទទួលសេវាគ្រប់គ្រង ពី ម.ម.ជ ស្របតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។ ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា មានទំហំ ខ្នាតជាច្រើន ត្រូវបានបែងចែក សម្រាប់បិទភ្ជាប់ ឬ បោះពុម្ព ដោយអនុលោមទៅតាមទំហំ ប្រភេទឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ប្រការ២:** ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ត្រូវបានកំណត់សម្គាល់ ទំហំខ្នាត តូច ឬធំបាន ដោយត្រូវសមាមាត្រទៅនឹងគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ និងបញ្ជាក់អត្ថន័យដូចតទៅ:

ពមក : ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាប្រើ (FONT LIMON S2)

**MTC** : **Metrology Trademark of Cambodia** ប្រើ (**FONT Times New Roman**)

**00X** : លេខកូដចុះបញ្ជីក្រុមហ៊ុន ឬប្រកាសបង្កើត រោងចក្រ សិប្បកម្ម ឬចុះបញ្ជីសិប្បកម្ម

**00M** : លេខរៀងចុះបញ្ជីមាត្រាសាស្ត្រ

**YY** : ថ្ងៃ ខែ ឆ្នាំ ចុះបញ្ជីមាត្រាសាស្ត្រ

ប្រអប់រាងចតុកោណកែង សម្រាប់សម្គាល់ការប្រើ ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ដែលមានលំនាំអក្សរកាត់ **MTC: 00X/00M/YY** ។

MTC: 00X/00M/YY

**ប្រការ៣** : ត្រូវបានកំណត់ពណ៌ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ទៅតាមភាពជាក់ស្តែងសម្រាប់បិទភ្ជាប់ ឬបោះពុម្ពទៅលើប្រភេទ ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់។ ពណ៌ និងទំហំ នៃពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ត្រូវមានការបញ្ជាក់ច្បាស់លាស់ ក្នុងកិច្ចព្រមព្រៀងរវាង មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងអ្នកស្នើសុំ។

**ប្រការ៤** : ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដែលផលិត នាំចូល ដំឡើង ប្រើប្រាស់ ជួសជុល ថែទាំ និងអាចលក់ ឬ ដាក់តាំងលក់ បាននូវឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និង ទំនិញវេចខ្ចប់ ឬ អនុញ្ញាតឲ្យ ប្រើប្រាស់ កាន់កាប់ក្នុងសកម្មភាព ពាណិជ្ជកម្ម និងវិស័យផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវតែមកធ្វើការ ស្នើសុំវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ ដើម្បីទទួលបានសិទ្ធិស្នើសុំ អាជ្ញាប័ណ្ណប្រើប្រាស់ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**ប្រការ៥** : រាល់ខ្លឹមសារប្រកាសលេខ ៦៦០ ឧរថ.មមជ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ២០១១ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

ស៊ុយ_សែម

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន សេនាធិការ ក្រសួង ឧ.រ.ថ
- គ្រប់នាយកដ្ឋាន សេនាធិការ ក្រសួង ឧ.រ.ថ

"ដើម្បីជូនជ្រាប"
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត

"ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា




មាត្រដ្ឋាន: ១/១